# ថ្នាំបង្ការជំងឺ COVID-19 សម្រាប់កុមារដែលមានអាយុចាប់ពី 6 ខែឡើងទៅ
## សំណួរដែលបានសួរជាញឹកញាប់សម្រាប់ឪពុកម្តាយ និងអាណាព្យាបាល

**ការចាក់ថ្នាំបង្ការគឺមិនគិតថ្លៃជានិច្ច។ ទាំងអ្នក ឬក៏កូនរបស់អ្នកនឹងមិនមានការសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។**
**សូមចូលទៅកាន់គេហទំព័រៈ VaccinateLACounty.com ឬ VacunateLosAngeles.com (ភាសាអេស្ប៉ាញ) ដើម្បីស្វែងរកទីតាំងចាក់ថ្នាំបង្ការ។**

## ហេតុអ្វីបានជាកូនរបស់ខ្ញុំគួរតែចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺ COVID-19?

ការចាក់ថ្នាំបង្ការសម្រាប់កូនរបស់អ្នក គឺជាវិធីដ៏ល្អបំផុតដើម្បីការពារពួកគេពីការឆ្លងជំងឺ COVID-19។ ការចាក់ថ្នាំបង្ការក៏ជួយការពារពួកគេ ពីបញ្ហាសុខភាពរយៈពេលវែងដែលបណ្តាលមកពីជំងឺ COVID-19 ផងដែរ។

បើទោះបីជាជំងឺ COVID-19 ច្រើនតែមានកម្រិតស្រាលចំពោះកុមារក៏ដោយ ក៏ពួកគេអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរបានផងដែរ។ រហូតមកដល់ពេលនេះ ជំងឺ COVID-19 បានបង្ក ឬចូលរួមចំណែកដល់ ការស្លាប់នៃកុមារចំនួនច្រើនជាង 1900 នាក់។ កុមារមួយចំនួនដែលមានជំងឺកម្រិតស្រាលពីដំបូងនោះ កើតមានរោគសញ្ញានៃការរលាកពហុសរីរាង្គចំពោះកុមារ (MIS-C) ក្នុងអំឡុងពេល ពីរទៅបីសប្តាហ៍ក្រោយមក។ នេះគឺជាស្ថានភាពមួយដែលផ្នែកផ្សេងៗនៃរាងកាយអាចមានការរលាក រួមមានទាំងបេះដូង សួត តម្រងនោម ខួរក្បាល ស្បែក ភ្នែក ឬសរីរាង្គក្រពះពោះវៀនផងដែរ។

ដូចគ្នានឹងអ្វីដែលកើតមានចំពោះមនុស្សពេញវ័យនោះ ក៏មានកុមារដែលបានឆ្លងមេរោគ និងជួបប្រទះនឹងស្ថានភាពក្រោយមានជំងឺ COVID-19 ផងដែរ ឬហៅថា “ជំងឺ COVID រយៈពេលវែង” បើទោះបីជាការឆ្លងជំងឺ COVID របស់ពួកគេគឺមានកម្រិតស្រាលក៏ដោយ។ កុមារទាំងឡាយដែលមានជំងឺ COVID រយៈពេលវែង អាចនឹងមានអារម្មណ៍អស់ កម្លាំង ឈឺក្បាល និងមានបញ្ហាក្នុងការផ្តោតអារម្មណ៍។ សភាពនេះអាចកើតមានរយៈពេលជាច្រើនសប្តាហ៍រហូតដល់ជាច្រើនខែ បន្ទាប់ពីបានឆ្លងជំងឺ COVID-19 រួច។ ការសិក្សាជាច្រើនបានបង្ហាញថា "ជំងឺ COVID រយៈពេលវែង" កើតមានឡើងជាញឹកញាប់ជាងចំពោះកុមារទាំងឡាយដែលមិនបានចាក់ថ្នាំបង្ការ។

សូម្បីតែកុមារដែលមានសុខភាពល្អ ហើយដែលមិនមានបញ្ហាសុខភាពប្រចាំកាយ ក៏អាចត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមានបញ្ហាសុខភាពរយៈពេលវែងដែលអាចប៉ះពាល់ដល់សុខភាពផ្លូវចិត្តនិងផ្លូវកាយ ហើយនិងកម្រិតនៃការរស់នៅរបស់ពួកគេផងដែរ។ ការធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 នៅតែ គ្រប់លក្ខណៈនិងទាន់ពេលវេលា រួមទាំងដូសជំរុញ អាចកាត់បន្ថយហានិភ័យនៃការទទួលរងបញ្ហាទាំងនេះបាន។

## អាចចាក់ថ្នាំបង្ការប្រភេទណា និងអាចចាក់បាននៅពេលណា

## តើថ្នាំបង្ការជំងឺ COVID-19 ណាខ្លះដែលកូនរបស់ខ្ញុំអាចទទួលចាក់បាន?

មានការណែនាំឱ្យកុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។ កូនរបស់អ្នកអាចទទួលចាក់ថ្នាំបង្ការប្រភេទណាមួយក៏បាន ក្នុងចំណោមថ្នាំបង្ការជំងឺ COVID-19 នានាដែលបានទទួលការអនុញ្ញាត ឬបានទទួលការអនុម័តឱ្យប្រើប្រាស់សម្រាប់ក្រុមអាយុរបស់ពួកគេៈ

- កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែឡើងទៅ អាចទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬក៏ប្រភេទ Moderna បាន។
- កុមារទាំងឡាយដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ អាចទទួលចាក់ថ្នាំបង្ការប្រភេទ Novavax បាន។

កម្រិតដូសនៃថ្នាំបង្ការ គឺអាស្រ័យទៅលើអាយុរបស់កុមារ នៅនឹងថ្ងៃដែលពួកគេទទួលចាក់ថ្នាំបង្ការនោះ ហើយមិនមែនអាស្រ័យទៅលើកម្ពស់ ឬទម្ងន់របស់ពួកគេនោះទេ។ នេះគឺជាកម្រិតដូសដែលចាំបាច់ ដើម្បីបង្កើតការឆ្លើយតបនៃភាពស៊ាំ ដែលត្រឹមត្រូវ។ កុមារទាំងឡាយដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ទទួលចាក់ដូសថ្នាំបង្ការដែលមានកម្រិតដូចគ្នាទៅនឹងដូសសម្រាប់យុវវ័យ និងមនុស្សពេញវ័យ។

ចំនួនដូស និងពេលវេលារវាងដូសនីមួយៗ គឺអាស្រ័យទៅលើប្រភេទថ្នាំបង្ការដែលកូនរបស់អ្នកបានទទួលចាក់ អាយុរបស់ពួកគេ និងថាតើពួកគេ មានប្រព័ន្ធភាពស៊ាំចុះខ្សោយ ឬទេ។

សូមមើលគេហទំព័រ ph.lacounty.gov/covidvaccineschedules សម្រាប់ព័ត៌មានលម្អិតអំពីការណែនាំនានាចំពោះថ្នាំបង្ការសម្រាប់កុមារទាំងឡាយ។ សូមមើល តារាងព័ត៌មានការពិតរបស់រដ្ឋបាលចំណីអាហារនិងឱសថ សម្រាប់អ្នកទទួលចាក់ថ្នាំបង្ការ និងអ្នកផ្តល់ការថែទាំ (FDA Fact Sheets for Recipients and Caregivers) ចំពោះថ្នាំបង្ការប្រភេទ Pfizer ប្រភេទ Moderna ឬក៏ប្រភេទ Novavax សម្រាប់ព័ត៌មានអំពីថ្នាំបង្ការនីមួយៗ។ សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។

## កាលវិភាគបានបង្ហាញថាគួរតែមានការផ្តល់ជូនដូសទី 2 នៃថ្នាំបង្ការបាន រហូតដល់រយៈពេល 8

## សប្ដាហ៍ បន្ទាប់ពីបានទទួលចាក់ដូសទីមួយរួច។ តើខ្ញុំអាចសម្រេចចិត្តបានយ៉ាងដូចម្ដេចថា តើកូនរបស់ខ្ញុំគួរតែទទួលចាក់ដូសទីពីរនៅពេលណា?

ពេលវេលាដែលបានណែនាំសម្រាប់ការទទួលចាក់ដូសលំដាប់ដំបូងទី 2 របស់កូនអ្នក គឺអាស្រ័យទៅលើស្ថានភាពរបស់កុមារនីមួយៗ។

- មានការណែនាំឱ្យទុកគម្លាត *រយៈពេល 3 សប្ដាហ៍* (ប្រភេទ Pfizer និងប្រភេទ Novavax) ឬក៏ *រយៈពេល 4 សប្ដាហ៍* (ប្រភេទ Moderna) បន្ទាប់ពីបានទទួលចាក់ដូសទី 1 រួច សម្រាប់កុមារដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យម ឬកម្រិតធ្ងន់ធ្ងរ។ ហើយនេះក៏ជាការណែនាំផងដែរ នៅពេលដែលត្រូវការប្រព័ន្ធការពារដែលពេញលេញបំផុតតាមដែលអាចធ្វើបាន ឱ្យបានកាន់តែឆាប់ជាងមុននោះ ឧទាហរណ៍ ដូចជានៅពេលដែលមានកម្រិតនៃការរីករាលដាលនៅក្នុងសហគមន៍ខ្ពស់ ឬក៏បុគ្គលម្នាក់ប្រឈមនឹងហានិភ័យខ្ពស់ជាងមុនក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។
- *រយៈពេល 8 សប្ដាហ៍* បន្ទាប់ពីបានទទួលចាក់ដូសទី 1 រួច អាចជាគម្លាតរយៈពេលដ៏ល្អបំផុតសម្រាប់កុមារមួយចំនួន ជាពិសេសយុវជន និងមនុស្សពេញវ័យនៅក្មេងភេទប្រុស (ដែលមានអាយុចាប់ពី 12 ទៅ 39 ឆ្នាំ)។ នេះគឺពីព្រោះតែការទុកគម្លាតរយៈពេលរវាងដូសទីមួយ និងដូសទីពីរឱ្យបានយូរជាងមុន អាចនឹងជួយបង្កើនប្រសិទ្ធិភាពនៃថ្នាំបង្ការទាំងឡាយបាន។ បន្ថែមពីនេះ ការធ្វើបែបនេះក៏អាចជួយកាត់បន្ថយកម្រិតហានិភ័យនៃបញ្ហារលាកសាច់ដុំបេះដូង (ម៉ាយអូខាដាយធីស/myocarditis) និងបញ្ហារលាកស្រទាប់ខាងក្រៅនៃបេះដូង (ភែរីខាដាយធីស/pericarditis) (ជាស្ថានភាពបេះដូងផ្សេងៗ) ដែលកម្រនឹងកើតមានស្រាប់នោះ ផងដែរ។

## តើថ្នាំបង្ការជំងឺ COVID-19 ដើម (បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent) មានភាពខុសគ្នាពីថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញ (បែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent) យ៉ាងដូចម្ដេច?

ថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន (monovalent) ប្រឆាំងដោយផ្ទាល់ទៅនឹងមេរោគដើមដែលបង្កឱ្យមានជំងឺ COVID-19។ ថ្នាំបង្ការផ្សេងៗត្រូវបានកែប្រែដើម្បីបង្កើតទៅជាថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន (bivalent) ដែលប្រឆាំងដោយផ្ទាល់ទៅនឹងមេរោគដើមនៃជំងឺ COVID-19 ហើយនិងមេរោគប្រភេទ Omicron BA.4 និង BA.5 ផងដែរ។

- *ដូសលំដាប់ដំបូង* - ថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន ប្រើប្រាស់ជាលំដាប់ដំបូងសម្រាប់ថ្នាំបង្ការទាំងអស់ ដោយមានចំណុចលើកលែងមួយ។ ថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន ប្រើប្រាស់ជាដូសទី 3 នៃលំដាប់ដំបូងប្រភេទ Pfizer សម្រាប់កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ។
- *ដូសជំរុញ* - ដូសជំរុញប្រភេទ Pfizer និងប្រភេទ Moderna ទាំងអស់គឺជាថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន (ដែលបានធ្វើឱ្យថ្មីឡើងវិញ)។ ដូសជំរុញប្រភេទ Novavax គឺជាថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន។

## តើកូនរបស់ខ្ញុំគួរតែចាក់ដូសជំរុញ ដែរឬទេ?

**ចាស/បាទ។ មានការណែនាំឱ្យមនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (បែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent) ដោយមានចំណុចលើកលែងមួយ។** កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ ហើយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Pfizer មិនមានសិទ្ធិទទួលចាក់ដូសជំរុញទេ នាពេលនេះ។

ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញនេះ (updated booster) អាចជួយធ្វើឱ្យប្រព័ន្ធការពារប្រឆាំងនឹងជំងឺ COVID-19 មានភាពដូចដើមឡើងវិញ ដែលប្រព័ន្ធការពារនេះបានចុះអន់ថយទៅតាមពេលវេលា ហើយនិងជួយផ្ដល់ប្រព័ន្ធការពារដែលទូលំទូលាយជាងមុន ប្រឆាំងនឹងប្រភេទមេរោគថ្មីៗ ផងដែរ។ ដូសជំរុញប្រភេទ Pfizer និងប្រភេទ Moderna ដើម (បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent) គឺលែងមានសម្រាប់ប្រើប្រាស់ហើយ។

មានការណែនាំឱ្យទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញចំនួនមួយដូស ក្នុងរយៈពេលយ៉ាងហោចណាស់ 2 ខែ បន្ទាប់ពីការចាក់ដូសថ្នាំបង្ការជំងឺ COVID-19 ចុងក្រោយបង្អស់ (ជាដូសលំដាប់ដំបូង ឬដូសជំរុញដើម [បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន] [monovalent] ចុងក្រោយបង្អស់) របស់កូនអ្នក។

ការចាក់បែបនេះគឺមិនគិតអំពី ថាតើបានទទួលចាក់ដូសជំរុញដើម (បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent) ប៉ុន្មានដូសហើយ ពីពេលកន្លងមកនោះទេ។ កុមារទាំងឡាយដែលមានអាយុចាប់ពី 11 ឆ្នាំ ចុះក្រោម ទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញនេះ ក្នុងកម្រិតតិចជាងដូសសម្រាប់យុវវ័យ និងមនុស្សពេញវ័យ។

*អាយុចាប់ពី 5 ឆ្នាំឡើងទៅ*

- កុមារទាំងឡាយដែលមានអាយុ 5 ឆ្នាំ ហើយដែលបានបញ្ចប់ការចាក់លំដាប់ដំបូងប្រភេទ Moderna អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Pfizer ឬប្រភេទ Moderna ក៏បាន។
- កុមារទាំងឡាយដែលមានអាយុ 5 ឆ្នាំ ហើយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Pfizer អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Pfizer។
- មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ឆ្នាំឡើងទៅ អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Pfizer ឬប្រភេទ Moderna ក៏បាន។

*អាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ*

- កុមារទាំងឡាយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Moderna អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Moderna។
- កុមារទាំងឡាយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Pfizer មិនមានសិទ្ធិទទួលចាក់ដូសជំរុញទេ នាពេលនេះ។ កំណត់សម្គាល់៖ លំដាប់ដំបូងប្រភេទ Pfizer សម្រាប់ក្រុមអាយុនេះ រាប់បញ្ចូលថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន (bivalent) (បែបដែលបានធ្វើឱ្យថ្មីឡើងវិញ) សម្រាប់ដូសទី 3ហើយ នាពេលឥឡូវនេះ។

សូមចូលទៅកាន់គេហទំព័រ ការស្វែងយល់អំពីពេលដែលត្រូវទទួលចាក់ដូសជំរុញ ដែលអាចផ្លាស់ប្តូរព័ត៌មានគ្នាបានរបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ដើម្បីជួយកំណត់ថាតើកូនរបស់អ្នក អាចទទួលចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 មួយឬច្រើន បានឬទេ។ សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។

## តើកូនរបស់ខ្ញុំគួរតែចាក់ថ្នាំបង្ការដែរឬទេ ប្រសិនបើពួកគេធ្លាប់មានជំងឺ COVID-19 រួចហើយនោះ?

ចាស/បាទ។ កូនរបស់អ្នកគួរតែធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 នៅតែ គ្រប់លក្ខណៈនិងទាន់ពេលវេលា បើទោះបីជាពួកគេធ្លាប់មានជំងឺ COVID-19 រួចហើយក៏ដោយ។ ការធ្វើបែបនេះគឺពីព្រោះតែថ្នាំបង្ការទាំងឡាយផ្តល់នូវប្រព័ន្ធការពារខ្ពស់ជាងមុន។

ការឆ្លងជំងឺ COVID-19 ផ្តល់នូវប្រព័ន្ធការពារមួយចំនួនពីការធ្លាក់ខ្លួនឈឺដោយសារជំងឺ COVID-19 នាពេលអនាគត ដែលពេលខ្លះត្រូវបានហៅថា "ប្រព័ន្ធភាពស៊ាំដោយធម្មជាតិ"។ ប៉ុន្តែកម្រិតនៃប្រព័ន្ធការពារដែលមនុស្សម្នាក់ទទួលបានពីការឆ្លងមេរោគរួចនោះមានភាពខុសគ្នា។ កម្រិតនេះអាស្រ័យទៅលើ ថាតើជំងឺរបស់ពួកគេមានកម្រិតស្រាល ឬធ្ងន់ធ្ងរ ពេលវេលាដែលបានកន្លងផុតទៅចាប់តាំងពីពេលដែលពួកគេបានឆ្លងជំងឺ COVID-19 ហើយនិងអាយុរបស់ពួកគេ ផងដែរ។ នាពេលឥឡូវនេះ មិនមានការធ្វើតេស្តណាមួយដែលអាចបង្ហាញយ៉ាងត្រឹមត្រូវថា តើមនុស្សម្នាក់មានប្រព័ន្ធការពារពីការឆ្លងជំងឺ COVID-19 ឬអត់នោះទេ។ ការសិក្សា មួយដែលបានបោះពុម្ពផ្សាយនាខែកក្កដា ឆ្នាំ 2022 បានបង្ហាញថា នៅពេលដែលមនុស្សដែលបានឆ្លងជំងឺ COVID-19 នាពេលកន្លងមកនោះ បានទទួលចាក់ថ្នាំបង្ការ ពួកគេបានបង្កើតការឆ្លើយតបនៃភាពស៊ាំដែលខ្លាំងមួយ ហើយមានប្រព័ន្ធការពារដែលកាន់តែប្រសើរប្រឆាំងនឹងការឆ្លងជំងឺ COVID-19 ជាងអ្នកដែលមិនបានទទួលចាក់ថ្នាំបង្ការ។

ប្រសិនបើកូនរបស់អ្នកធ្លាប់ជំងឺ COVID-19 នាពេលថ្មីៗនេះ អ្នកអាចពិចារណាធ្វើការរង់ចាំរយៈពេល 3 ខែ បន្ទាប់ពីកូនរបស់អ្នកបានកើតជំងឺ COVID-19 ពីដំបូងរួច ដើម្បីចាប់ផ្តើម ឬបន្តការចាក់លំដាប់ថ្នាំបង្ការជំងឺ COVID-19 ឬ ចាក់ដូសជំរុញ។ ការធ្វើបែបនេះគឺពីព្រោះតែពួកគេមិនទំនងជានឹងកើតជំងឺ COVID-19 ម្តងទៀតក្នុងអំឡុងពេល 3 ខែដំបូង បន្ទាប់ពីការឆ្លងរួចនោះទេ។ គម្លាតពេលវេលាកាន់តែវែងរវាងការឆ្លងមេរោគ និងការទទួលចាក់ថ្នាំបង្ការ ក៏អាចនឹងធ្វើឱ្យទទួលបានការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំកាន់តែប្រសើរផងដែរ។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនគួររង់ចាំចាក់ដូសនោះលើសពី រយៈពេល 3 ខែនោះទេ ហើយការទទួលចាក់ថ្នាំបង្ការឱ្យបានកាន់តែឆាប់ គឺមានសុវត្ថិភាពផងដែរ។ ប្រសិនបើកូនរបស់អ្នកមានជំងឺ COVID-19 នាពេលឥឡូវនេះ អ្នកគួរតែរង់ចាំយ៉ាងហោចណាស់រហូតដល់ពេលដែលការដាក់ខ្លួនឱ្យនៅដាច់ដោយឡែករបស់ពួកគេបានបញ្ចប់

ដើម្បីទៅទទួលចាក់ថ្នាំបង្ការ។ ការធ្វើបែបនេះគឺដើម្បីកុំឱ្យពួកគេចម្លងមេរោគបន្តទៅបុគ្គលិកផ្នែកថែទាំសុខភាព និងអ្នកដទៃ នៅពេលដែលពួកគេទៅទទួលចាក់ថ្នាំបង្ការនោះ។

ប្រសិនបើកូនរបស់អ្នកមានរោគសញ្ញានៃការរលាកពហុសរីរាង្គចំពោះកុមារ (MIS-C) សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់ពួកគេ ថាតើមានការណែនាំឱ្យទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 នៅពេលណា។

## សុវត្ថិភាពទាក់ទងនឹងថ្នាំបង្ការជំងឺ COVID-19

### តើមានសុវត្ថិភាពដែរឬទេ សម្រាប់កុមារក្នុងការទទួលការចាក់ថ្នាំបង្ការ?

ចាស/បាទ ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 គឺមានសុវត្ថិភាពសម្រាប់កុមារ។ មុនពេលធ្វើការណែនាំឱ្យមានការចាក់ថ្នាំបង្ការជំងឺ COVID-19 ដល់កុមារ មានការធ្វើតេស្តសាកល្បងតាមបែបវេជ្ជសាស្ត្រ (clinical trials) ព្យាបាលកុមាររាប់ពាន់នាក់ ដើម្បីសាកល្បងអំពីសុវត្ថិភាព និងប្រសិទ្ធិភាពរបស់ថ្នាំបង្ការសម្រាប់ក្រុមអាយុនេះ។

រហូតមកដល់ពេលនេះ កុមារ និងយុវវ័យរាប់សិបលាននាក់ ដែលមានអាយុចាប់ពី 5 ទៅ 17 ឆ្នាំ ហើយនិងកុមារដែលមានអាយុចាប់ពី 4 ឆ្នាំចុះក្រោម ច្រើនជាងមួយលាននាក់ បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 យ៉ាងហោចណាស់មួយដូស។ ការតាមដានផ្នែកសុវត្ថិភាពដែលកំពុងបន្តមាន បង្ហាញឱ្យឃើញថាថ្នាំបង្ការជំងឺ COVID-19 នៅតែមានសុវត្ថិភាពសម្រាប់កុមារ និងយុវវ័យ។

ជាធម្មតា ផលប៉ះពាល់ផ្សេងៗមានកម្រិតស្រាល និងឆាប់បាត់ទៅវិញ។ ប្រតិកម្ម ឬការទាស់ធ្ងន់ធ្ងរ បន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ចំពោះកុមារនានាគឺកម្រនឹងកើតមាន ហើយជាធម្មតាកើតមានឡើងនៅប៉ុន្មានថ្ងៃបន្ទាប់ពីការទទួលចាក់ថ្នាំបង្ការរួច។

*បញ្ហា myocarditis និងបញ្ហា pericarditis*
មានការរាយការណ៍ថាករណីដែលកម្រនឹងកើតមានចំពោះបញ្ហា myocarditis (ម៉ាយអូខាដាយធីស/ការរលាកសាច់ដុំបេះដូង) និងបញ្ហា pericarditis (ភែរីខាដាយធីស/ការរលាកស្រទាប់ខាងក្រៅនៃបេះដូង) បានកើតមានឡើងបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬប្រភេទ Moderna ឬក៏ប្រភេទ Novavax។ ករណីភាគច្រើនកើតឡើងក្នុងចំណោមមនុស្សភេទប្រុសដែលមានអាយុចាប់ពី 12 ទៅ 39 ឆ្នាំ ហើយបន្ទាប់ពីការចាក់ថ្នាំបង្ការដូសទីពីររបស់ពួកគេ។ កម្រិតហានិភ័យនៃការកើតមានបញ្ហាកម្រទាំងនេះ អាចនឹងកាត់បន្ថយ នៅពេលដែលមានការទុក គម្លាតរយៈពេលកាន់តែវែង (8 សប្តាហ៍) មុនពេលទទួលចាក់ដូសទីពីរ សម្រាប់លំដាប់ដំបូងនៃថ្នាំបង្ការ។

ការរាយការណ៍ នាខែកញ្ញា ឆ្នាំ 2022 មួយពីមជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) បានរកឃើញថាមិនមានការកើនឡើងនៃកម្រិតហានិភ័យសម្រាប់បញ្ហារលាកសាច់ដុំបេះដូងចំពោះកុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 5 ឆ្នាំ នោះទេ។

ការសិក្សា មួយទៅលើមនុស្សដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ បានរកឃើញថាហានិភ័យនៃការមានបញ្ហាបេះដូង ដូចជាបញ្ហារលាកសាច់ដុំបេះដូងនោះ មានកម្រិតកាន់តែខ្ពស់នៅពេលមានការកើតជំងឺ COVID-19 ជាងបន្ទាប់ពីការទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna។ ការរកឃើញនេះ កើតឡើងចំពោះទាំងប្រុស និងស្រី។ ការកត់សម្គាល់ជាសំខាន់ផងដែរនោះគឺថា បញ្ហារលាកសាច់ដុំបេះដូងដែលបង្កឡើងបន្ទាប់ពីការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 មានកម្រិតស្រាលជាង ហើយមិនកើតមានរយៈពេលយូរ ដូចបញ្ហារលាកសាច់ដុំបេះដូងដោយសារហេតុផលផ្សេងទៀតនោះទេ។ មនុស្សភាគច្រើនដែលមានបញ្ហារលាកសាច់ដុំបេះដូង ឬបញ្ហារលាកស្រទាប់ខាងក្រៅនៃបេះដូង បន្ទាប់ពីការចាក់ថ្នាំបង្ការរួចនោះ នឹងមានការប្រសើរឡើងវិញដោយប្រើប្រាស់ថ្នាំពេទ្យ និងការសម្រាកថែទាំសុខភាព។

សូមស្វែងរកជំនួយផ្នែកថែទាំសុខភាពភ្លាមៗ ប្រសិនបើកូនរបស់អ្នកឈឺទ្រូង ដកដង្ហើមខ្លីៗ មានអារម្មណ៍ថាបេះដូងលោតញាប់ ឬលោតខុសធម្មតា ឬក៏លោតខ្លាំង។

សូមស្វែងយល់បន្ថែមនៅលើគេហទំព័រ បញ្ហារលាកសាច់ដុំបេះដូង និងបញ្ហារលាកស្រទាប់ក្រៅនៃបេះដូងបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ mRNA របស់ CDC។

*បញ្ហា anaphylaxis*
បញ្ហា anaphylaxis (អាណាហ្វីឡាក់ស៊ីស) គឺជាប្រតិកម្ម ឬការទាស់បែបធ្ងន់ធ្ងរមួយដែលអាចកើតឡើងបន្ទាប់ពីការទទួលចាក់ថ្នាំបង្ការរួច។ ប្រតិកម្ម ឬការទាស់ដែលមិនសូវធ្ងន់ធ្ងរដទៃទៀតក៏អាចកើតមានផងដែរ។ សូមទូរស័ព្ទទៅលេខ 911 ប្រសិនបើអ្នកគិតថា កូនរបស់អ្នកអាចនឹងមានការប្រតិកម្ម ឬការទាស់បែបធ្ងន់ធ្ងរ បន្ទាប់ពីបានចាកចេញពីទីតាំងផ្តល់ថ្នាំបង្ការហើយនោះ។

សូមស្វែងយល់បន្ថែមនៅលើគេហទំព័រ ប្រតិកម្ម ឬការទាស់នានាបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 របស់ CDC។

**CDC ណែនាំឱ្យមានការ ចាក់ថ្នាំបង្ការជំងឺ COVID-19 សម្រាប់មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ។ ហានិភ័យដែលបានដឹងអំពីជំងឺ COVID-19 រួមមានការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ បញ្ហាសុខភាពរយៈពេលវែង ហើយនិងការស្លាប់នោះ មានច្រើនជាងហានិភ័យនៃប្រតិកម្មអវិជ្ជមានទៅនឹងថ្នាំបង្ការដ៏កម្រផ្សេងៗ ដែលអាចនឹងកើតមាននោះ។**

## តើថ្នាំបង្ការមានផលប៉ះពាល់អ្វីខ្លះចំពោះកុមារ?

ផលប៉ះពាល់ផ្សេងៗបន្ទាប់ពីទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ចំពោះកុមារគឺមានភាពស្រដៀងគ្នាទៅនឹងអ្វីដែលកើតឡើងចំពោះមនុស្សពេញវ័យផងដែរ។ ផលប៉ះពាល់ផ្សេងៗដែលកើតមានចំពោះកុមារតូចៗ គឺដូចគ្នាទៅនឹងក្រោយពេលដែលពួកគេចាក់ថ្នាំបង្ការជំងឺតាមទម្លាប់ផ្សេងៗទៀតផងដែរ ហើយច្រើនតែកើតមានឡើងក្រោយពេលទទួលចាក់ដូសទីពីរ។ ផលប៉ះពាល់ផ្សេងៗពីការចាក់ដូសជំរុញទំនងជានឹងស្រដៀងគ្នា ឬមានកម្រិតតិចជាងផលប៉ះពាល់ផ្សេងៗក្រោយពីការចាក់ដូសលំដាប់ដំបូង។

ផលប៉ះពាល់ទូទៅរួមមាន ការឈឺ ឡើងហើម ឬឡើងក្រហមនៅនឹងដៃឬភ្លៅ នៅត្រង់កន្លែងដែលបានចាក់ថ្នាំបង្ការនោះ ការឈឺតាមសន្លាក់ឬឈឺសាច់ដុំ ការហើមកូនកណ្តុរ គ្រុនក្តៅ គ្រុនរងា ឈឺក្បាល ឆាប់ខឹងឬឆាប់យំ មានអារម្មណ៍អស់កម្លាំង ងងុយគេង និងបាត់បង់ចំណង់អាហារ។

ផលប៉ះពាល់ទាំងនេះអាចដាក់កម្រិតទៅលើសកម្មភាពប្រចាំថ្ងៃមួយចំនួន ប៉ុន្តែគួរតែបាត់ទៅវិញក្នុងរយៈពេលពីរទៅបីថ្ងៃក្រោយ។ មិនមែនមនុស្សគ្រប់គ្នានឹងកើតមានផលប៉ះពាល់ទាំងនេះទេ។ ផលប៉ះពាល់ទាំងនេះគឺជារឿងធម្មតា និងជាសញ្ញាដែលបង្ហាញថារាងកាយកំពុងបង្កើតភាពស៊ាំ។

## តើកូនរបស់ខ្ញុំអាចកើតជំងឺ COVID-19 ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 ដែរឬទេ?

ទេ។ កូនរបស់អ្នកមិនអាចកើតជំងឺ COVID-19 ពីការថ្នាំបង្ការនេះទេ។ ចំណុចនេះមិនអាចទៅរួចទេ។ មិនមានថ្នាំបង្ការណាមួយដែលមានប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក មានផ្ទុកនូវទម្រង់ណាមួយនៃមេរោគដែលបង្កឱ្យមានជំងឺ COVID-19 ឡើយ។

## តើការទទួលចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺ COVID-19 ហើយនិងថ្នាំបង្ការជំងឺដទៃទៀតក្នុងពេលតែមួយ មានសុវត្ថិភាពសម្រាប់កូនរបស់ខ្ញុំ ដែរឬទេ?

ចាស/បាទ។ កុមារដែលមានអាយុចាប់ពី 6 ខែឡើងទៅ អាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ក្នុងពេលតែមួយនឹងថ្នាំបង្ការជំងឺតាមទម្លាប់ពេលនៅកុមារភាពដទៃទៀតបាន ដូចជាថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង (polio) ជំងឺគ្រុនផ្តាសាយធំ (flu) ឬ MMR (measles, mumps, and rubella/កញ្ជ្រឹល ស្រឡទែន និងស្អូច) ហើយនិង Tdap (Tetanus, Diphtheria, and Pertussis/តេតាណូស ខាន់ស្លាក់ និងក្អកមាន់) ផងដែរ។ ប្រសិនបើកូនរបស់អ្នកទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 នៅកន្លែងមួយដែលមិនមានផ្តល់ជូនថ្នាំបង្ការផ្សេងទៀតដែលពួកគេអាចនឹងត្រូវការទេនោះ អ្នកអាចធ្វើដំណើរទៅកាន់ទីតាំងផ្សេងមួយទៀតដើម្បីចាក់ថ្នាំបង្ការទាំងនោះ នៅពេលណាក៏បាន។ មិនចាំបាច់ចំណាយពេលរង់ចាំសម្រាប់ចាក់ថ្នាំបង្ការផ្សេងគ្នានោះទេ។

## តើកុមារដែលមានប្រតិកម្ម ឬការទាស់ អាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 បាន ដែរឬទេ?

ចំណុចនេះអាស្រ័យទៅអ្វីដែលកុមារនោះមានប្រតិកម្ម ឬការទាស់ជាមួយ។

- កុមារដែលមានប្រតិកម្ម ឬការទាស់ជាមួយនឹងរបស់មួយចំនួនដូចជាថ្នាំលេប អាហារ (រួមទាំងស៊ុត) សារធាតុជ័រកៅស៊ូ សត្វចង្រៃ ឬលម្អងផ្កា ឬក៏មានប្រវត្តិគ្រួសារទាក់ទងនឹងប្រតិកម្ម ឬការទាស់ ក៏អាចចាក់ថ្នាំបង្ការបានដែរ។ ថ្នាំបង្ការទាំងនេះមិនមានផ្ទុកសារធាតុប្រូតេអ៊ីនផ្សេងៗពីអាហារ (ដូចជាស៊ុត ឬផលិតផលគ្រាប់ធញ្ញជាតិ) ចាហួយ សារធាតុជ័រកៅស៊ូ ថ្នាំប្រឆាំងមេរោគ (antibiotics) លោហៈធាតុ ឬសារធាតុគីមីទុកកុំឱ្យខូច (ដូចជាសារធាតុសម្រាប់ទប់ស្កាត់ការដុះផ្សិត [thimerosal] ឬជាតិបារត [mercury]) ឡើយ។ សូមស្វែងយល់បន្ថែមចំពោះគ្រឿងផ្សំគឺជាអ្វី និងមិនមែនជាអ្វី នៅក្នុងថ្នាំបង្ការជំងឺ COVID-19 នីមួយៗ នៅទីនេះ។
- ចូរពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ប្រសិនបើកូនរបស់អ្នកមានប្រតិកម្ម ឬការទាស់ជាមួយនឹងថ្នាំបង្ការ ឬការព្យាបាលដោយការចាក់ម្ជុល (បើទោះបីជាប្រតិកម្មឬការទាស់នោះមិនធ្ងន់ធ្ងរក៏ដោយ)។ គ្រូពេទ្យនឹងជួយសម្រេចចិត្តថាតើការចាក់ថ្នាំបង្ការសម្រាប់ពួកគេមានសុវត្ថិភាព ឬទេ។

- អ្នកដែលមានប្រតិកម្ម ឬការទាស់ជាមួយនឹងសារធាតុចម្រាញ់ពីប្រេង ប៉ូលីអេស៊ីលីនគ្លីកូល (polyethylene Glycol, PEG) មិនគួរទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna នោះទេ។ អ្នកដែលមានប្រតិកម្ម ឬការទាស់ជាមួយនឹងសារធាតុ ប៉ូលីសរបឺត (polysorbate) មិនគួរទទួលចាក់ថ្នាំបង្ការប្រភេទ Novavax នោះទេ។

**ព័ត៌មានអំពីប្រតិកម្ម ឬការទាស់អាចនឹងមានការផ្លាស់ប្តូរ។ ដើម្បីពិនិត្យមើលការណែនាំថ្មីបំផុត សូមមើលគេហទំព័រ ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 របស់អ្នក ហើយនិង ប្រតិកម្ម ឬការទាស់បន្ទាប់ពីការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ហើយពិគ្រោះជាមួយនឹងគ្រូពេទ្យ។**

## តើថ្នាំបង្ការបណ្តាលឱ្យមិនមានកូន ដែរឬទេ?

ទេ ថ្នាំបង្ការមិនបណ្តាលឱ្យមិនមានកូននោះទេ។ មិនមានភ័ស្តុតាងណាមួយដែលបង្ហាញថា ថ្នាំបង្ការណាមួយ រួមទាំងថ្នាំបង្ការជំងឺ COVID-19 ផងដែរនោះ បណ្តាលឱ្យមានបញ្ហាមិនមានកូនសម្រាប់ស្ត្រី ឬបុរសឡើយ។ បន្ថែមពីនេះ មិនមានភ័ស្តុតាងណាមួយដែលបង្ហាញថាគ្រឿងផ្សំរបស់ថ្នាំបង្ការ រួមទាំង mRNA ឬក៏សារធាតុទប់ទល់នឹងជំងឺ ឬអង់ទីក័រ (antibodies) ដែលបានបង្កើតឡើងបន្ទាប់ពីបានទទួលថ្នាំបង្ការ COVID-19 ហើយនោះ នឹងបណ្តាលឱ្យនរណាម្នាក់មានបញ្ហាមិនមានកូន (ទោះជានៅពេលនេះ ឬនាពេលអនាគត) នោះឡើយ។ ការសិក្សាជាច្រើនមិនបានបង្ហាញអំពីភាពខុសគ្នានៃអត្រាក្នុងការមានផ្ទៃពោះ ចំពោះស្ត្រីនិងបុរសដែលបានចាក់ថ្នាំបង្ការ ហើយនិងស្ត្រីនិងបុរសដែលមិនបានទទួលចាក់ថ្នាំបង្ការនោះទេ។ ថ្នាំបង្ការមិនផ្លាស់ប្តូរ DNA របស់មនុស្សទេ។ មិនមានភ័ស្តុតាងណាមួយដែលបញ្ជាក់ថាថ្នាំបង្ការជំងឺ COVID-19 ប៉ះពាល់ដល់ភាពពេញវ័យ ឬការលូតលាស់របស់យុវវ័យឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ ថ្នាំបង្ការជំងឺ COVID-19 សម្រាប់មនុស្សដែលចង់មានកូន របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

## តើថ្នាំបង្ការជំងឺ COVID-19 អាចប៉ះពាល់ដល់ការមានរដូវកូនរបស់ខ្ញុំ ដែរឬទេ?

មនុស្សមួយចំនួនបានធ្វើការរាយការណ៍អំពីការផ្លាស់ប្តូររដូវរបស់ពួកគេ បន្ទាប់ពីចាក់ថ្នាំបង្ការជំងឺ COVID-19 រួច។ ការសិក្សា នាពេលថ្មីៗនេះចំនួនពីរបានរកឃើញថា ពេលវេលាចន្លោះពីវដ្តរដូវមួយទៅវដ្តរដូវមួយទៀតនោះ មានការកើនឡើង ជាមធ្យម ចំនួនតិចជាងមួយថ្ងៃ នៅក្នុងវដ្តរដូវនីមួយៗដែលបុគ្គលនោះទទួលចាក់ថ្នាំបង្ការ។ មិនមានការផ្លាស់ប្តូរទៅលើចំនួនថ្ងៃដែលមានធ្លាក់ឈាមនោះទេ។ ការផ្លាស់ប្តូរទាំងនេះគឺបណ្តោះអាសន្នតែប៉ុណ្ណោះ។

សូមចងចាំជាសំខាន់ថា មានចំណុចជាច្រើនដែលអាចបណ្តាលឱ្យមានការផ្លាស់ប្តូរនៃវដ្តរដូវ។ ចំណុចទាំងនេះរួមមាន ភាពតានតឹង ការផ្លាស់ប្តូរការគេង របបអាហារ ការធ្វើលំហាត់ប្រាណ និងការប្រើប្រាស់ថ្នាំមួយចំនួនផងដែរ។ វដ្តរដូវមិនទៀងទាត់គឺជារឿងធម្មតាណាស់ចំពោះយុវវ័យទាំងឡាយ ហើយក៏អាចនឹងមិនមានមូលហេតុជាក់លាក់នោះដែរ។ ប្រសិនបើកូនរបស់អ្នកមានការព្រួយបារម្ភអំពីរដូវរបស់ពួកគេ មានការណែនាំឱ្យពួកគេពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់ពួកគេ។

## តើថ្នាំបង្ការជំងឺ COVID-19 នឹងមានផលប៉ះពាល់រយៈពេលវែងដល់កូនរបស់ខ្ញុំ ដែរឬទេ?

ទេ។ មនុស្សរាប់ពាន់លាននាក់បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ហើយមិនមានការកត់សម្គាល់ថាមានផលប៉ះពាល់រយៈពេលវែងដែលមិនបានដឹងជាមុននោះទេ។ ផ្អែកលើអ្វីដែលយើងដឹងអំពីថ្នាំបង្ការផ្សេងទៀត ផលប៉ះពាល់ដ៏កម្រណាមួយ ជាធម្មតាចាប់ផ្តើមលេចឡើងក្នុងរយៈពេលប្រាំមួយសប្តាហ៍បន្ទាប់ពីការទទួលចាក់ថ្នាំបង្ការ។ ចំពោះហេតុផលនេះ រដ្ឋបាលចំណីអាហារនិងឱសថ (FDA) បានតម្រូវចាំបាច់ឱ្យមានការសិក្សាទៅលើថ្នាំបង្ការជំងឺ COVID-19 នីមួយៗ យ៉ាងហោចណាស់រយៈពេលប្រាំបីសប្តាហ៍បន្ទាប់ពីការចាក់ដូសចុងក្រោយ មុនពេលពួកគេផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់។ បន្ថែមពីនេះ មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) នៅតែបន្តតាមដានថ្នាំបង្ការជំងឺ COVID-19 ទាំងនេះ បន្ទាប់ពីថ្នាំបង្ការទាំងនេះបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ហើយ។

ផ្ទុយទៅវិញ យើងពិតជាដឹងថាមេរោគដែលបង្កឱ្យមានជំងឺ COVID-19 អាចបណ្តាលឱ្យមានផលប៉ះពាល់រយៈពេលវែងជាច្រើនចំពោះកុមារ។ ឧទាហរណ៍ មនុស្សមួយចំនួនបន្តមានរោគសញ្ញានានា ដូចជាមានអារម្មណ៍នឿយហត់ខ្លាំង ពិបាកក្នុងការគេង ឈឺក្បាល និងដកដង្ហើមខ្លីៗ អស់រយៈពេលជាច្រើនខែ បន្ទាប់ពីការឆ្លងជំងឺ COVID-19 លើកដំបូងរបស់ពួកគេហើយដែលជាទូទៅ ត្រូវបានហៅថាជាជំងឺ COVID រយៈពេលវែង (long COVID)។ លើសពីនេះទៅទៀត ស្ថានភាពធ្ងន់ធ្ងរមួយដែលហៅថា រោគសញ្ញានៃការរលាកពហុសរីរាង្គ (Multi-System Inflammatory Syndrome) (MIS-C) អាចប៉ះពាល់ដល់កុមារ ផងដែរ។ នេះគឺជាស្ថានភាពសុខភាពដ៏កម្រ ប៉ុន្តែធ្ងន់ធ្ងរមួយ ដែលទាក់ទងទៅនឹង COVID-19 ហើយដែលធ្វើឱ្យផ្នែកផ្សេងៗនៃរាងកាយបង្កជាការរលាក រួមទាំងបេះដូង សួត តម្រងនោម ខួរក្បាល ស្បែក ភ្នែក ឬសរីរាង្គក្រពះពោះវៀន ផងដែរ។ អ្នកជំងឺជាច្រើនត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយ

ជាអកុសល អ្នកខ្លះអាចស្លាប់ទៀតផង។ ការចាក់ថ្នាំបង្ការជំងឺ COVID-19 ផ្តល់នូវប្រព័ន្ធការពារខ្លះប្រឆាំងនឹងផលប៉ះពាល់ "រយៈពេលវែង" នៃមេរោគនេះ។ អ្នកអាចស្វែងយល់បន្ថែមតាមរយៈការចូលទៅកាន់គេហទំព័រ សុវត្ថិភាពនៃថ្នាំបង្ការជំងឺ COVID-19 របស់ CDC។

## ប្រសិនបើកូនរបស់ខ្ញុំមានប្រតិកម្មអវិជ្ជមាន (ផលប៉ះពាល់ដែលអាចកើតមាន) បន្ទាប់ពីពួកគេបានចាក់ថ្នាំបង្ការរួច តើខ្ញុំអាចធ្វើការរាយការណ៍បានយ៉ាងដូចម្តេច?

ប្រសិនបើកូនរបស់អ្នកមានប្រតិកម្មអវិជ្ជមានបន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការរួច សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ហើយធ្វើការរាយការណ៍អំពីប្រតិកម្មនោះទៅប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍អវិជ្ជមានចំពោះថ្នាំបង្ការ (ឬ VAERS)។ ធ្វើការរាយការអំពីផលប៉ះពាល់នេះ បើទោះបីជាអ្នកមិនប្រាកដថាបង្កឡើងដោយថ្នាំបង្ការក៏ដោយ។ VAERS គឺជាប្រព័ន្ធព្រមានដំបូងដែលរដ្ឋបាលចំណីអាហារនិងឱសថ (FDA) ហើយនិងមជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ប្រើប្រាស់ដើម្បីស្វែងរកបញ្ហាផ្នែកសុវត្ថិភាពដែលអាចកើតមានដោយថ្នាំបង្ការណាមួយ។ ដើម្បីធ្វើការរាយការណ៍ សូមទូរស័ព្ទទៅលេខ 1-800-822-7967 ឬចូលទៅកាន់គេហទំព័រ https://vaers.hhs.gov/reportevent.html។

ប្រសិនបើអ្នកមានទូរស័ព្ទទំនើប អ្នកអាចជួយ CDC ពិនិត្យតាមដានថ្នាំបង្ការនានាបាន តាមរយៈការចុះឈ្មោះកូនរបស់អ្នកក្នុងកម្មវិធី v-Safe។ **V-safe** គឺជាកម្មវិធីដែលមានសម្រាប់ប្រើប្រាស់នៅក្នុងទូរស័ព្ទទំនើប ហើយដែលផ្ញើសារជាអក្សរដើម្បីពិនិត្យមើលកូនរបស់អ្នក បន្ទាប់ពីពួកគេបានទទួលចាក់ថ្នាំបង្ការរួច។ គួរតែមានការចុះឈ្មោះសម្រាប់កុមារម្នាក់ៗដាច់ដោយឡែករៀងៗខ្លួន។ រាល់សារជាអក្សររបស់កម្មវិធី V-Safe នឹងត្រូវផ្ញើទៅកាន់ទូរស័ព្ទទំនើបរបស់ឪពុកម្តាយ ឬអាណាព្យាបាល។

មិនត្រូវប្រើប្រាស់ប្រព័ន្ធ VAERS និងកម្មវិធី v-safe សម្រាប់ដំបូន្មានផ្នែកសុខភាពនោះទេ។ សូមទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នក ឬស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ ប្រសិនបើកូនរបស់អ្នកមានរោគសញ្ញា ឬបញ្ហាសុខភាពនានាដែលធ្វើឱ្យអ្នកព្រួយបារម្ភ បន្ទាប់ពីការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 រួច។

# ការចាក់ថ្នាំបង្ការឱ្យកុមារ

## តើខ្ញុំអាចចាក់ថ្នាំបង្ការសម្រាប់កូនរបស់ខ្ញុំនៅទីណាបាន?

ថ្នាំបង្ការមានផ្តល់ជូននៅទីតាំងរាប់រយកន្លែងនៅទូទាំងខោនធី LA។ ទីតាំងទាំងនេះរួមមានការិយាល័យគ្រូពេទ្យជំនាញខាងកុមារ គ្លីនិក ឱសថស្ថាន សាលារៀន ទីតាំងចាក់ថ្នាំបង្ការជំងឺ COVID-19 ពិសេស និងទីតាំងចល័តជា ច្រើនទៀត។ អ្នកមិនចាំបាច់មានការណាត់ជួបទេ សម្រាប់ទីតាំងជាច្រើន។

ការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏មានផ្តល់ជូនផងដែរ សម្រាប់មនុស្សដែលមិនអាចធ្វើដំណើរចេញពីផ្ទះបាន។

ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ៖ ph.lacounty.gov/howtogetvaccinated។ អ្នកក៏អាចទូរស័ព្ទទៅមជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីថ្នាំបង្ការ (Vaccine Call Center) តាមរយៈលេខ 1-833-540-0473។ ទីតាំងនេះបើកបម្រើការជូនជារៀងរាល់ថ្ងៃចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់ ហើយអាចរៀបចំការធ្វើដំណើរដោយមិនគិតថ្លៃទៅកាន់ទីតាំងចាក់ថ្នាំបង្ការ ហើយនិងការចាក់ថ្នាំបង្ការនៅតាមផ្ទះផងដែរ។ សូមប្រាកដថាជ្រើសរើសទីតាំងដែលមានផ្តល់ជូនថ្នាំបង្ការដែលសមស្របសម្រាប់អាយុរបស់កូនអ្នក។ សូមកត់សម្គាល់ថាឱសថស្ថានភាគច្រើនមិនអាចផ្តល់ថ្នាំបង្ការដល់កុមារដែលមានអាយុក្រោម 3 ឆ្នាំនោះទេ។

## តើថ្នាំបង្ការជំងឺ COVID-19 គឺមិនគិតថ្លៃ មែនឬទេ?

មែនហើយ ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយគឺមិនគិតថ្លៃទេ និងមានផ្តល់ជូនសម្រាប់បុគ្គលគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ។ ថ្នាំបង្ការជំងឺ COVID-19 នឹងបន្តផ្តល់ជូនដល់បុគ្គលដែលមានសិទ្ធិទទួលបាន ហើយដែលរស់នៅក្នុងសហរដ្ឋអាមេរិកគ្រប់រូប ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ ឬស្ថានភាពធានារ៉ាប់រងឡើយ។ ទីតាំងផ្តល់ថ្នាំបង្ការអាចនឹងសួររកប័ណ្ណធានារ៉ាប់រងសុខភាពរបស់អ្នក ក៏ប៉ុន្តែនេះមិនមែនជាការតម្រូវចាំបាច់ឱ្យមានដើម្បីឱ្យកូនរបស់អ្នកអាចទទួលចាក់ថ្នាំបង្ការនោះឡើយ។

## តើខ្ញុំអាចទទួលបានកំណត់ត្រានៃការចាក់ថ្នាំបង្ការជាលក្ខណៈឌីជីថលសម្រាប់កូនរបស់ខ្ញុំដោយរបៀបណា?

ប្រសិនបើកូនរបស់អ្នកបានទទួលចាក់ថ្នាំបង្ការនៅក្នុងរដ្ឋ California ពួកគេនឹងទទួលបានប័ណ្ណកំណត់ត្រានៃការចាក់ថ្នាំបង្ការពណ៌ស មួយសន្លឹក។ អ្នកក៏អាចស្នើសុំកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ជាលក្ខណៈឌីជីថល តាមរយៈគេហទំព័រ myvaccinerecord.cdph.ca.gov

ផងដែរ។ នេះគឺជាកំណត់ត្រាផ្លូវការ។ កំណត់ត្រានេះអាចទាញយកទៅដាក់ក្នុងកម្មវិធី Google Pay នៅលើទូរស័ព្ទប្រភេទ Android ឬកម្មវិធី Apple Health នៅលើទូរស័ព្ទប្រភេទ iPhone ផងដែរ។ អ្នកអាចទទួលបានកំណត់ត្រាសម្រាប់មនុស្សម្នាក់ៗនៅក្នុងក្រុមគ្រួសាររបស់អ្នក បើទោះបីជាអ្នកបានប្រើប្រាស់អាសយដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទដែដូចគ្នានៅពេលដែលពួកគេបានទទួលចាក់ថ្នាំបង្ការក៏ដោយ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ កំណត់ត្រានៃការចាក់ថ្នាំបង្ការ។

## តើខ្ញុំត្រូវផ្ដល់ការអនុញ្ញាតដើម្បីឱ្យកូនរបស់ខ្ញុំអាចទទួលចាក់ថ្នាំបង្ការបាន មែនឬទេ?

យុវវ័យដែលមានអាយុក្រោម 18 ឆ្នាំត្រូវការការអនុញ្ញាតពីឪពុកម្ដាយ/អាណាព្យាបាល ឬអ្នកផ្ដល់ការមើលថែទាំ ដើម្បីទទួលចាក់ថ្នាំបង្ការបាន។ ប្រសិនបើអ្នកមិនអាចមានវត្តមានបានទេ អ្នកអាចនឹងផ្ដល់ការអនុញ្ញាតតាមទូរស័ព្ទ តាមវីដេអូ ឬជាលាយលក្ខណ៍អក្សរបាន។ សូមពិនិត្យមើលតម្រូវការចាំបាច់នៃការអនុញ្ញាតនៅទីតាំងដែលអ្នកមានគម្រោងនឹងទៅ។ ប្រសិនបើនោះជាទីតាំងដែលគ្រប់គ្រងដោយនាយកដ្ឋានសុខភាពសាធារណៈ (Public Health) អ្នកអាចរកមើលតម្រូវការចាំបាច់ផ្សេងៗ និងទាញយកបែបបទនៃការអនុញ្ញាតតាមរយៈគេហទំព័រ ph.lacounty.gov/ howtogetvaccinated។ សូមចុចលើ "ការត្រៀមខ្លួនសម្រាប់ដំណើរទៅរបស់អ្នក (Preparing for your visit)" ឬទូរស័ព្ទទៅមជ្ឈមណ្ឌលផ្ដល់ព័ត៌មានអំពីថ្នាំបង្ការ (Vaccine Call Center) តាមរយៈលេខ 1-833-540-0473 (បើកបម្រើការជូនចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ)។

ករណីលើកលែងមួយចំនួននឹងត្រូវអនុវត្ត។ អនីតិជន (ជនមិនទាន់គ្រប់អាយុ) ដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅ ហើយដែលអាចទទួលខុសត្រូវដោយខ្លួនឯងបាន (ឧទាហរណ៍ អនីតិជនដែលមានសិទ្ធិស្របច្បាប់ ឬដែលអាចទទួលខុសត្រូវដោយខ្លួនឯង ឬក៏បានរៀបការរួចហើយ ឬធ្លាប់បានរៀបការពីពេលមុន) អាចផ្ដល់ការអនុញ្ញាតដោយខ្លួនឯងបាន។ ប្រសិនបើអ្នកគឺជាអ្នកចិញ្ចឹមមើលថែទាំ ឬជាសាច់ញាតិមើលថែទាំ ឬក៏ជាបុគ្គលិកកម្មវិធីព្យាបាលឱ្យស្នាក់នៅរយៈពេលខ្លី (STRTP) អ្នកអាចផ្ដល់ការអនុញ្ញាតបាន ដរាបណាកុមារចិញ្ចឹមនោះយល់ព្រមផងដែរ។ ប្រសិនបើអ្នកគឺជាអ្នកចិញ្ចឹមមើលថែទាំ ហើយអ្នកមិនផ្ដល់ការអនុញ្ញាតទេ ប៉ុន្តែកូនចិញ្ចឹមរបស់អ្នកចង់ទទួលចាក់ថ្នាំបង្ការនោះ ពួកគេអាចទាក់ទងទៅអ្នកប្រឹក្សាខាងច្បាប់របស់ពួកគេបាន។

## តើខ្ញុំត្រូវការនាំយកឯកសារអ្វីខ្លះទៅជាមួយ ដើម្បីចាក់ថ្នាំបង្ការឱ្យកូនរបស់ខ្ញុំ?

ទីតាំងចាក់ថ្នាំបង្ការមួយចំនួនអាចនឹងតម្រូវចាំបាច់ឱ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថត។ ប្រសិនបើអ្នកគឺជាអាណាព្យាបាលរបស់កុមារម្នាក់ ដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំ ហើយកូនចិញ្ចឹមរបស់អ្នកមិនមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតទេនោះ សូមឱ្យពួកគេទាក់ទងទៅអ្នកប្រឹក្សាខាងច្បាប់របស់ពួកគេ។ ជម្រើសមួយទៀត គឺត្រូវទៅកាន់ទីតាំងដែលគ្រប់គ្រងដោយនាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (Los Angeles County Department of Public Health) ដែលមិនតម្រូវចាំបាច់ឱ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតនោះទេ។

សូមមើលផ្នែកខាងលើ សម្រាប់ព័ត៌មានអំពីការអនុញ្ញាត។ សូមពិនិត្យមើលតម្រូវការចាំបាច់នៃទីតាំងដែលអ្នកមានគម្រោងនឹងទៅ។ ព័ត៌មានទាំងនេះអាចនឹងរកបាននៅលើគេហទំព័ររបស់ទីតាំងទាំងនោះ ឬនៅក្នុងអ៊ីម៉ែល ឬក៏សារជាអក្សរដែលបញ្ជាក់អំពីការណាត់ជួបនោះ។ សម្រាប់ព័ត៌មានអំពីតម្រូវការចាំបាច់នៅតាមទីតាំងចាក់ថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/howtogetvaccinated។ សូមចុចលើ "ការត្រៀមខ្លួនសម្រាប់ដំណើរទៅរបស់អ្នក (Preparing for your visit)" ឬទូរស័ព្ទទៅមជ្ឈមណ្ឌលផ្ដល់ព័ត៌មានអំពីថ្នាំបង្ការ (Vaccine Call Center) តាមរយៈលេខ 1-833-540-0473 (បើកបម្រើការជូនចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ)។

## តើខ្ញុំត្រូវនិយាយជាមួយនឹងកូនរបស់ខ្ញុំអំពីការចាក់ថ្នាំបង្ការជំងឺ COVID-19 បានយ៉ាងដូចម្ដេច?

ការដែលមនុស្សវ័យក្មេងដឹងអំពីការពិតនៃថ្នាំបង្ការជំងឺ COVID-19 គឺជាការសំខាន់។ មានព័ត៌មានមិនពិតជាច្រើនអំពីជំងឺ COVID-19 និងថ្នាំបង្ការជំងឺនេះ ត្រូវបានផ្សព្វផ្សាយនៅលើអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ សូមប្រាកដថា និយាយជាមួយនឹងកូនរបស់អ្នកអំពីជំងឺ COVID-19 ហើយឆ្លើយនូវរាល់សំណួរដែលពួកគេអាចនឹងមាន។

សូមឱ្យពួកគេដឹងអំពីហានិភ័យនៃសុខភាព ប្រសិនបើមាននរណាម្នាក់កើតជំងឺ COVID-19 និងមូលហេតុដែលថា ការទទួលចាក់ថ្នាំបង្ការអាចជួយការពារពួកគេបាន។ ចូរពន្យល់ថា ថ្នាំបង្ការនេះមានសុវត្ថិភាព ហើយមិនមានផ្ទុកមេរោគនោះទេ។ ចូរពន្យល់អំពីផលប៉ះពាល់ជាមួយពួកគេឡើងវិញ ហើយឱ្យពួកគេបានដឹងថាផលប៉ះពាល់ទាំងនេះគឺជារឿងធម្មតាទេ។

លួងលោមពួកគេ ប្រសិនបើពួកគេព្រួយបារម្ភអំពីការចាក់ថ្នាំបង្ការ។ សូមនិយាយដោយស្មោះត្រង់ និងរក្សាអារម្មណ៍

ឱ្យស្ងប់។ ចំណាយពេលពន្យល់រៀបរាប់អំពីចំណុចដែលត្រូវរំពឹងទុក។ ពោលគឺ ប្រាប់ឱ្យកូនរបស់អ្នកបានដឹងថាពួកគេអាចនឹងមានអារម្មណ៍ប្រៀបដូចជាស្រមោចខាំឬការក្តិចបន្តិច ហើយនឹងបាត់ទៅវិញយ៉ាងឆាប់រហ័ស។ ចូរប្រើប្រាស់ពាក្យ ដូចជា "សង្កត់" ឬ "ចុច" ជាជាងពាក្យដូចជា "ឈឺ" ឬ "ចាក់"។ បើទោះបីជាកូនរបស់អ្នកមិនយល់អំពីន័យរបស់ពាក្យដែលអ្នកនិយាយក៏ដោយ ប៉ុន្តែសម្លេងដោយស្ងប់របស់អ្នក នឹងជួយធ្វើឱ្យពួកគេមានទំនុកចិត្តបាន។ ចូររក្សាភាពរីករាយនិងបន្ធូរអារម្មណ៍ មុនពេល ក្នុងអំឡុងពេល និងជាពិសេសក្រោយពេលទទួលចាក់ថ្នាំបង្ការរួច។

ប្រសិនបើកូនរបស់អ្នកខ្លាចម្ជុល សូមមើលគេហទំព័រ ការខ្លាចព្រួញនិងជំងឺខ្លាចម្ជុល - ស្វែងរកវិធីសាស្ត្រនានាដើម្បីដោះស្រាយ របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

សូមប្រើប្រាស់ធនធាន កូនសៀវភៅណែនាំអំពីការចាក់ថ្នាំបង្ការជំងឺ COVID-19 សម្រាប់កូនរបស់អ្នក របស់នាយកដ្ឋានសុខភាពសាធារណៈ (DPH) ដែលបានបង្កើតឡើងដើម្បីជួយដល់ឪពុកម្តាយនិងអ្នកផ្តល់ការថែទាំក្នុងការរៀបចំនិងកត់ត្រាអំពីការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 របស់កូនពួកគេ។

## តើខ្ញុំអាចធ្វើអ្វីបានខ្លះ ដើម្បីរៀបចំសម្រាប់ការធ្វើដំណើរទៅទីកន្លែងចាក់ថ្នាំបង្ការជំងឺ COVID-19 សម្រាប់កូនរបស់ខ្ញុំ?

ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 គឺទំនងជាស្រដៀងគ្នាទៅនឹងការទទួលចាក់ថ្នាំបង្ការជំងឺតាមទម្លាប់ផ្សេងៗផងដែរ។ គន្លឹះទាំងឡាយខាងក្រោមអាចជួយឱ្យមានភាពងាយស្រួលជាងមុនសម្រាប់អ្នក និងកូនរបស់អ្នក នៅពេលដែលពួកគេទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។

*មុនពេលការធ្វើដំណើរទៅ របស់អ្នក*

- **ស្វែងរកទីតាំងចាក់ថ្នាំបង្ការដែលសមស្របសម្រាប់កូនរបស់អ្នក**
  - **ចូរពិនិត្យមើលថាតើទីតាំងចាក់ថ្នាំបង្ការនោះ មានផ្តល់ជូននូវប្រភេទថ្នាំបង្ការដែលសមស្របសម្រាប់ក្រុមអាយុរបស់កូនអ្នកដែរ ឬយ៉ាងណា។** ចូរកត់សម្គាល់ថាឱសថស្ថានជាច្រើនមិនអាចផ្តល់ថ្នាំបង្ការសម្រាប់កុមារដែលមានអាយុក្រោម 3 ឆ្នាំនោះទេ។
  - **ចូរពិនិត្យមើលនូវតម្រូវការចាំបាច់នានាទាក់ទងនឹងការអនុញ្ញាត និងការនាំយកឯកសារទៅ។** អ្នកអាចនឹងដឹងអំពីតម្រូវការចាំបាច់ទាំងនោះបាននៅលើគេហទំព័ររបស់ទីតាំងទាំងនោះ ឬក៏នៅក្នុងអ៊ីម៉ែល ឬសារជាអក្សរដែលបញ្ជាក់អំពីការណាត់ជួប។ សម្រាប់ព័ត៌មានអំពីតម្រូវការចាំបាច់ទាំងឡាយនៅតាមទីតាំងចាក់ថ្នាំបង្ការនានារបស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA (LA County Department of Public Health) សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/vaccineappointment។ សូមចុចលើ 'ការត្រៀមខ្លួនសម្រាប់ដំណើរទៅរបស់អ្នក (Preparing for your visit)'។
- **ជូនដំណឹងដល់បុគ្គលថា ប្រសិនបើកូនរបស់អ្នកត្រូវការការធ្វើឱ្យមានភាពងាយស្រួលផ្សេងៗ នៅពេលដែលអ្នកធ្វើការណាត់ជួប** (ឬពេលដែលអ្នកទៅដល់ទីកន្លែងនោះ ប្រសិនបើនោះជាទីកន្លែងដែលមិនត្រូវការឱ្យមានការណាត់ជួបទេនោះ)។ តាមផ្លូវច្បាប់ មានការអនុញ្ញាតឱ្យសត្វបម្រើសេវាកម្ម (service animals) ទាំង ឡាយ អមដំណើរកុមារនៅតាមទីកន្លែងចាក់ថ្នាំបង្ការជំងឺ COVID-19 ផ្សេងៗ។ ប្រសិនបើអ្នកត្រូវការព័ត៌មានអំពី សេវាកម្មមធ្យោបាយធ្វើដំណើរសម្រាប់ជនពិការ (paratransit services) ក៏ដូចជាមធ្យោបាយធ្វើដំណើរទៅកន្លែងចាក់ថ្នាំបង្ការដោយមិនគិតថ្លៃ ឬក៏ ការចាក់ថ្នាំបង្ការនៅតាមផ្ទះ សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/howtogetvaccinated។ អ្នកក៏អាចទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីថ្នាំបង្ការ របស់ DPH (DPH Vaccine Call Center) បានផងដែរ តាមរយៈលេខ 1-833-540-0473 ដែលមានបើកបម្រើការជូនជារៀងរាល់ថ្ងៃចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់។ ព័ត៌មានបន្ថែមទៀតអាចរកបាននៅលើគេហទំព័រ ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 សម្រាប់កុមារ និងយុវវ័យទាំងឡាយដែលមានពិការភាព របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។
- **អានព័ត៌មានអំពីថ្នាំបង្ការ** ដែលមាននៅក្នុងការបញ្ជាក់អំពីការណាត់ជួបរបស់អ្នក។ ចូរសរសេររាល់សំណួរនានាដែលអ្នកអាចនឹងមាន។
- **ស្វែងយល់អំពីផលប៉ះពាល់ដែលអាចនឹងកើតមាន និងវិធីគ្រប់គ្រងផលប៉ះពាល់ទាំងនោះ នៅលើគេហទំព័រ**

**ផលប៉ះពាល់ទាំងឡាយរបស់ថ្នាំបង្ការជំងឺ COVID-19 របស់នាយកដ្ឋានសុខភាពសាធារណៈ។**

- **និយាយជាមួយកូនរបស់អ្នកអំពីអ្វីដែលត្រូវរំពឹងទុក។** សូមមើលចំណុច *តើខ្ញុំត្រូវនិយាយជាមួយនឹងកូនរបស់ខ្ញុំអំពីការចាក់ថ្នាំបង្ការជំងឺ COVID-19 បានយ៉ាងដូចម្តេច?* នៅខាងលើ។

*នៅនឹងថ្ងៃនៃការធ្វើដំណើរទៅ របស់កូនអ្នក*

- **មិនត្រូវឱ្យថ្នាំពេទ្យដែលអាចទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជា ដល់កូនរបស់អ្នកមុនពេលទទួលចាក់ថ្នាំបង្ការ** [ដូចជាថ្នាំបំបាត់ការឈឺចាប់ ឬថ្នាំប្រឆាំងនឹងប្រតិកម្មឬការទាស់ (antihistamines)] ដើម្បីជួយទប់ស្កាត់ផលប៉ះពាល់នានា នោះទេ លុះត្រាតែកូនរបស់អ្នកប្រើប្រាស់ថ្នាំទាំងនេះជាប្រចាំដោយសារមូលហេតុផ្សេងទៀត។
- **នាំយកទៅជាមួយនូវកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 របស់កូនអ្នក** ប្រសិនបើពួកគេធ្លាប់បានទទួលចាក់ថ្នាំបង្ការពីមុនមកហើយ។
- **នាំយកទៅជាមួយនូវរបស់របរដែលអាចផ្តល់ការលួងលោមដល់កូនរបស់អ្នកបាន** ដូចជារបស់លេង ភួយ ឬសៀវភៅ ដែលចូលចិត្តជាងគេ។
- **នាំយកទៅជាមួយនូវម៉ាស់ការពារ។** បុគ្គលគ្រប់រូប រួមទាំងបុគ្គលិក ក៏ដូចជាអ្នក និងកូនរបស់អ្នក (ប្រសិនបើមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ) ផងដែរ ត្រូវតែពាក់ម៉ាស់នៅទីតាំងចាក់ថ្នាំបង្ការនោះ។
- **នាំយកទៅជាមួយនូវអាហារសម្រន់ និងទឹក។** ប្រសិនបើអ្នកធ្វើដំណើរទៅទីតាំងដែលនៅបរិវេណខាងក្រៅអគារ ហើយនៅថ្ងៃដែលមានអាកាសធាតុក្តៅគួរសម សូមពាក់មួកនិងសម្លៀកបំពាក់ស្តើងៗ។
- **ស្វែងយល់អំពីគន្លឹះនានាក្នុងការផ្តល់ការគាំទ្រដល់កូនរបស់អ្នកមុនពេល ក្នុងអំឡុងពេល និងក្រោយពេលទទួលចាក់ថ្នាំបង្ការ**
  - គន្លឹះសម្រាប់គាំទ្រដល់កូនរបស់អ្នកសម្រាប់គ្រប់អាយុ ជាមួយនឹងការទទួលចាក់ថ្នាំបង្ការជំងឺតាមទម្លាប់ផ្សេងៗ មាននៅលើគេហទំព័រ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលចាក់ថ្នាំបង្ការ របស់ CDC។
  - ព័ត៌មានសម្រាប់ទារក មាននៅលើគេហទំព័រ ធ្វើឱ្យការទទួលចាក់ថ្នាំបង្ការមិនសូវមានភាពតានតឹង សម្រាប់ទារក របស់ CDC។ ទាំងនេះក៏រួមមានទាំងវិធីសាស្ត្របន្លប់ ការបំបៅកូនដោយទឹកដោះ ឬក៏ការស្នើសុំគ្រូពេទ្យឱ្យប្រើប្រាស់ទឹកលាយស្ករដែលផ្តល់តាមមាត់ និងថ្នាំលាបបំបាត់ការឈឺចាប់ ឬក៏ទឹកបាញ់ឱ្យត្រជាក់ផងដែរ។
  - ព័ត៌មានអំពីវិធីសាស្ត្រគ្រប់គ្រងការខ្លាចម្ជុល មាននៅលើគេហទំព័រ ការខ្លាចក្រែងនិងជំងឺខ្លាចម្ជុល របស់ CDC។

*នៅអំឡុងពេលនៅនឹងទីកន្លែង របស់អ្នក*

- **ប្រាប់អ្នកផ្តល់ថ្នាំបង្ការអំពីប្រតិកម្ម ឬការទាស់នានា** ដែលកូនរបស់អ្នកអាចនឹងមាន។
- **ប្រាប់ឱ្យកូនរបស់អ្នកអង្គុយចុះ ឬទម្រេតខ្លួនចុះនៅអំឡុងពេលទទួលចាក់ថ្នាំបង្ការ។** ពួកគេគួរតែបន្តអង្គុយចុះ ឬទម្រេតខ្លួនចុះឱ្យបានរយៈពេល 15 នាទីបន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការរួច។ ការធ្វើបែបនេះអាចជួយការពារពីការសន្លប់ និងការរងរបួសផ្សេងៗដែលពាក់ព័ន្ធទៅនឹងការសន្លប់។ សូមមើលគេហទំព័ររបស់ CDC សម្រាប់គន្លឹះផ្សេងៗអំពី របៀបកាន់ ឬពរកូនរបស់អ្នកនៅអំឡុងពេលទទួលចាក់ថ្នាំបង្ការ។ ការធ្វើបែបនេះនឹងជួយកាត់បន្ថយភាពតានតឹងរបស់កូនអ្នកហើយក៏អាចនឹងជួយធ្វើឱ្យមានភាពងាយស្រួលជាងមុនផងដែរ សម្រាប់អ្នកជំនាញផ្នែកថែទាំសុខភាពក្នុងការផ្តល់ថ្នាំបង្ការ។
- **សាកសួរអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់កូនអ្នក អំពីដំបូន្មានចំពោះការប្រើប្រាស់ថ្នាំបំបាត់ការឈឺចាប់ ដែលមិនមែនជាប្រភេទអាស្ពីរីន (non-aspirin pain reliever)។** សាកសួរអំពីវិធានការណ៍ផ្សេងៗ ដែលអ្នកអាចអនុវត្តនៅផ្ទះបាន ដើម្បីលួងលោមកូនរបស់អ្នក។
- **ត្រូវប្រាកដថាកូនរបស់អ្នកទទួលបានប័ណ្ណកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 របស់ពួកគេ។** សូមមើលគេហទំព័រ កំណត់ត្រានៃការចាក់ថ្នាំបង្ការ របស់នាយកដ្ឋានសុខភាពសាធារណៈសម្រាប់ព័ត៌មានអំពីប័ណ្ណនេះ និងកំណត់ត្រាជាលក្ខណៈឌីជីថលនានា។

- **ត្រូវប្រាកដថាអ្នកបានដឹងថា នៅពេលណាដែលដូសបន្ទាប់នៃថ្នាំបង្ការរបស់កូនអ្នកដល់ពេលកំណត់អាចទទួលបាន។** អ្នកអាចនឹងចង់ពិគ្រោះជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក អំពីពេលវេលាដែលល្អបំផុតសម្រាប់ទទួលចាក់ដូសទីពីរ។
- **ចុះឈ្មោះក្នុងកម្មវិធី V-safe។** V-safe គឺជាកម្មវិធីមួយដែលផ្តល់នូវការតាមដានសុខភាពដែលរហ័ស និងជាការសម្ងាត់ តាមរយៈសារជាអក្សរ និង/ឬការស្ទង់មតិតាមអនឡាញនានា។ អ្នកអាចចែករំលែកព័ត៌មានបាន យ៉ាងរហ័ស និងយ៉ាងងាយ ជាមួយនឹង CDC អំពីស្ថានភាពរបស់កូនអ្នកបន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 រួច។ ស្វែងយល់បន្ថែមនៅលើគេហទំព័រ កម្មវិធីតាមដានសុខភាពក្រោយការទទួលចាក់ថ្នាំបង្ការ របស់ V-safe និងចុះឈ្មោះនៅលើគេហទំព័រ vsafe.cdc.gov។

សូមប្រើប្រាស់ធនធាន “កូនសៀវភៅណែនាំអំពីការចាក់ថ្នាំបង្ការជំងឺ COVID-19 សម្រាប់កូនរបស់អ្នក” របស់នាយកដ្ឋានសុខភាពសាធារណៈ (DPH) ដែលបានបង្កើតឡើងដើម្បីជួយដល់ឪពុកម្តាយ និងអ្នកផ្តល់ការមើលថែទាំ ក្នុងការរៀបចំ និងកត់ត្រា3អំពីការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 របស់កូនពួកគេ។